**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ
## នៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍
## លើកទី៣២ ឆ្នាំ២០២៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល



www.pheakdeylaw.com

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

ត្រូវបានបង្កើត **គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍** ដែលសរសេរជាអក្សរកាត់ថា **គ.ជ.ប.អ.** និងសរសេរកាត់ជាភាសាអង់គ្លេស CAMSOC ដើម្បីជាយន្តការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍(SEA Games) លើកទី៣២ ឆ្នាំ២០២៣ ដែលព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួត។

## ជំពូកទី២
## សមាសភាពរបស់ គ.ជ.ប.អ.

**មាត្រា២ ._**

**គ.ជ.ប.អ.** មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងការពារជាតិ | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៦- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៧- តំណាងក្រសួងមហាផ្ទៃ១រូប | អនុប្រធាន |
| ៨- តំណាងក្រសួងទេសចរណ៍១រូប | អនុប្រធាន |
| ៩- អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ១០- អគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អគ្គលេខាធិការ |
| ១១- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប | អគ្គលេខាធិការរង |
| ១២- អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡានៃក្រសួងអប់រំ យុវជន និងកីឡា | អគ្គលេខាធិការរង |
| ១៣- តំណាងរដ្ឋមន្ត្រីក្រសួងការពារជាតិ១រូប | អគ្គលេខាធិការរង |

សមាសភាពជាក់ស្តែងរបស់ **គ.ជ.ប.អ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់ គ.ជ.ប.អ.

**មាត្រា៣ ._**

**គ.ជ.ប.អ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ គ្រប់គ្រង និងរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
- តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការមេនិងផែនការសកម្មភាពតាមដំណាក់កាលរបស់/...



www.pheakdeylaw.com

គណៈកម្មការនីមួយៗ
- សហការរៀបចំការប្រកួតកីឡាជាតិរៀងរាល់ពីរឆ្នាំម្តងជាមួយក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជានិងសហព័ន្ធកីឡាជាតិ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួង ស្ថាប័ន អង្គភាព រដ្ឋ អាជ្ញាធរ និងអង្គការកីឡាជាតិ វិស័យឯកជន ដែលពាក់ព័ន្ធនឹងយន្តការការងាររបស់ **គ.ជ.ប.អ.**
- ទទួលខុសត្រូវរៀបចំយុទ្ធសាស្ត្រ យុទ្ធវិធីក្នុងការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍ឱ្យមានសង្គតិភាពទៅនឹងស្តង់ដាសម្បទាកីឡាអន្តរជាតិ សមត្ថភាព គុណផលកីឡាកម្រិតខ្ពស់ ដើម្បីជានាឧត្តមភាពជាតិក្នុងនាមជាម្ចាស់ផ្ទះរៀបចំការប្រកួត
- បំផុស ផ្សព្វផ្សាយ លើកកម្ពស់ការចូលរួម អប់រំពីគុណតម្លៃកីឡា អត្ថប្រយោជន៍កីឡា និងទស្សនាទានកីឡានៃឥទ្ធិពលព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍នៅក្នុងសង្គមជាតិ
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរកីឡា គណៈកម្មាធិការជាតិអូឡាំពិកបណ្តាប្រទេសអាស៊ីអាគ្នេយ៍ សកលលោក និងជាមួយចលនាអូឡាំពិកអន្តរជាតិ ដើម្បីឆ្ពោះទៅរកប្រសិទ្ធភាពនៃដំណើរការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍
- កៀរគរធនធានហិរញ្ញវត្ថុនិងជំនួយផ្សេងៗពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិ
- រៀបចំបូកសរុបរបាយការណ៍វឌ្ឍនភាពការងារប្រចាំឆមាសជូនរាជរដ្ឋាភិបាល ១ឆ្នាំម្តងនិង២ឆ្នាំម្តងជូនក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ (SEAGF Council)
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## រចនាសម្ព័ន្ធរបស់ គ.ជ.ប.អ.

**មាត្រា៤._**

**គ.ជ.ប.អ.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- គណៈកម្មការសន្តិសុខនិងសណ្តាប់ធ្នាប់

២- គណៈកម្មការកីឡានិងបទប្បញ្ញត្តិ

៣- គណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់

៤- គណៈកម្មការហេដ្ឋា IT

៥- គណៈកម្មការទីលានប្រកួត

៦- គណៈកម្មការវេជ្ជសាស្ត្រនិងដូពីង

៧- គណៈកម្មការអ្នកស្ម័គ្រចិត្ត

៨- គណៈកម្មការវប្បធម៌ បរិស្ថាន និងអប់រំកីឡា

៩- គណៈកម្មការស្នាក់នៅនិងហូបចុក

១០- គណៈកម្មការផ្សព្វផ្សាយនិងព័ត៌មាន



www.pheakdeylaw.com

១១- គណៈកម្មការទីផ្សារនិងចលនូបត្ថម្ភ

១២- គណៈកម្មការដឹកជញ្ជូន

១៣- គណៈកម្មការពិធីការ

១៤- គណៈកម្មការពិធីបើកនិងបិទ

១៥- លេខាធិការដ្ឋាន

**គ.ជ.ប.អ.** អាចបង្កើតអនុគណៈកម្មការផ្សេងទៀតតាមការចាំបាច់ ដែលកំណត់ដោយប្រធាន **គ.ជ.ប.អ.**។

តួនាទីនិងភារកិច្ចរបស់គណៈកម្មការនីមួយៗនិងលេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.ប.អ.**។

សមាសភាពប្រធាននិងអនុប្រធានរបស់គណៈកម្មការនីមួយៗ និងលេខាធិការដ្ឋានត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៥

## ការប្រព្រឹត្តទៅរបស់ គ.ជ.ប.អ.

**មាត្រា៥ ._**

**គ.ជ.ប.អ.** មានការប្រជុំយ៉ាងតិច១ដង ក្នុង១ត្រីមាស។ ក្នុងករណីចាំបាច់ **គ.ជ.ប.អ.** អាចរៀបចំប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន។ ប្រធាន**គ.ជ.ប.អ.** ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន ឬ មានធុរៈចាំបាច់ អនុប្រធាន១រូបត្រូវដឹកនាំប្រជុំជំនួស។ សមាជិកនៃ**គ.ជ.ប.អ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា៦ ._**

ប្រធាន **គ.ជ.ប.អ.** អាចអញ្ជើញអ្នកជំនាញនិងតំណាងក្រសួងស្ថាប័នក្រៅពីសមាជិកនៃ**គ.ជ.ប.អ.** ចូលរួមប្រជុំតាមការចាំបាច់។

**គ.ជ.ប.អ.** អាចមានទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញបច្ចេកទេសជាតិនិងអន្តរជាតិតាមការចាំបាច់ ដើម្បីត្រួតពិនិត្យ ផ្ដល់យោបល់ និងតម្រង់ទិសលើការអនុវត្តផែនការអភិវឌ្ឍបច្ចេកទេសកីឡានិងបច្ចេកទេសគ្រប់គ្រងដឹកនាំព្រឹត្តិការណ៍កីឡា។

សមាសភាពនិងតួនាទីភារកិច្ចរបស់ទីប្រឹក្សាបច្ចេកទេស អ្នកជំនាញបច្ចេកទេសជាតិនិងអន្តរជាតិត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ជ.ប.អ.**។

**មាត្រា៧ ._**

**គ.ជ.ប.អ.** មានសិទ្ធិប្រើត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាដើម្បីដំណើរការការងាររបស់ខ្លួន។/ℕ



www.pheakdeylaw.com

## ជំពូកទី៦
## ប្រភពធនធាននិងថវិកា

**មាត្រា៨ .-**

ប្រភពធនធាននិងថវិកាសម្រាប់ដំណើរការ**គ.ជ.ប.អ.** ត្រូវប្រើកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាល។ **គ.ជ.ប.អ.** មានសិទ្ធិទទួលនិងគ្រប់គ្រង ចាត់ចែងប្រើប្រាស់ថវិកានិងធនធានទាំងអស់ដែលបានមកពីប្រភពផ្សេងៗសម្រាប់ដំណើរការការងាររបស់ខ្លួនជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១ កើត ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៧

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច លោកជំទាវ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com